ក្រសួងមហាផ្ទៃ
MINISTRY OF INTERIOR

unicef
ដើម្បីកុមារគ្រប់រូប

*សេចក្តីប្រកាសព័ត៌មាន*

## រាជរដ្ឋាភិបាល និងយូនីសេហ្វដាក់ដំណើរការយុទ្ធនាការជាតិដើម្បីទប់ស្កាត់ការរងរបួសចំពោះកុមារ

*ដោយមានកិច្ចគាំទ្រពីយូនីសេហ្វ និងដៃគូ រាជរដ្ឋាភិបាលកម្ពុជាកំពុងដាក់ដំណើរការយុទ្ធនាការជាតិចំនួនពីរ ដើម្បីទប់ស្កាត់ការស្លាប់របស់កុមារពីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក និងការលង់ទឹក ដែលជាមូលហេតុនាំមុខចំនួនពីរនៅក្នុងចំណោមមូលហេតុនាំមុខគេនៃការស្លាប់របស់កុមារ និងយុវជននៅកម្ពុជា។*

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥ - នាពេលបច្ចុប្បន្ននេះ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក និងការលង់ទឹក គឺជាមូលហេតុនាំមុខគេចំនួនពីរក្នុងចំណោមបុព្វហេតុនាំមុខគេនៃការស្លាប់របស់កុមារនៅប្រទេសកម្ពុជា ដែលបានធ្វើឱ្យកុមាររាប់ពាន់នាក់បានបាត់បង់ជីវិតជារៀងរាល់ឆ្នាំ។ ដោយមានការគាំទ្រពីយូនីសេហ្វ និងដៃគូ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ដំណើរការយុទ្ធនាការរួមគ្នា ដើម្បីការពារអាយុជីវិតកុមារពីសោកនាដកម្មដែលអាចបង្ការបាននេះ។

នៅឆ្នាំ២០២៣ តែមួយប៉ុណ្ណោះ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកបានសម្លាប់មនុស្សចំនួន ១.៥៩០នាក់ ពោលគឺ ជាមធ្យម មនុស្សប្រាំនាក់បានបាត់បង់ជីវិតជារៀងរាល់ថ្ងៃ និងបង្ករបួសដល់មនុស្សចំនួនច្រើនជាង ៤.៥០០នាក់ ដែលកុមារ និងយុវជនមានចំនួនច្រើនបំផុត[1]។ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក គឺជាឃាតករនាំមុខគេ ដែលសម្លាប់អាយុជីវិតរបស់យុវជនអាយុចន្លោះពី ១៥-១៩ឆ្នាំ[2] នៅក្នុងពិភពលោក។ ក្នុងចំណោមបណ្តាប្រទេសនៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ប្រទេសកម្ពុជាជាប្រទេសស្ថិតនៅលំដាប់កំពូលទីបី ដែលមានកុមារនិងយុវជនបាត់បង់ជីវិតដោយសារគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកខ្ពស់បំផុត[3]។

ទន្ទឹមនឹងនេះដែរ ប្រទេសកម្ពុជាប្រឈមមុខនឹងបញ្ហាធ្ងន់ធ្ងរផ្នែកសុខភាពសាធារណៈពាក់ព័ន្ធនឹងការលង់ទឹករបស់កុមារ ដែលធ្វើឱ្យមនុស្សចំនួន ១.៣០០នាក់ បាត់បង់ជីវិតជារៀងរាល់ឆ្នាំ។ ស្ថិតិដ៏សោកសៅនេះធ្វើឱ្យកម្ពុជាស្ថិតនៅក្នុងចំណោមប្រជាជាតិ ដែលមានអត្រាលង់ទឹកខ្ពស់បំផុតនៅតំបន់ប៉ាស៊ីហ្វិកខាងលិច[4]។ អត្រាលង់ទឹករបស់ប្រទេសកម្ពុជាស្ថិតក្នុងកម្រិត ៧,៦ នាក់ ក្នុងចំណោម ១០០.០០០នាក់ ដែលជាចំនួនស្ទើរតែទ្វេដងនៃចំនួនមធ្យមថ្នាក់តំបន់ (៤,៣នាក់ក្នុងចំណោម ១០០.០០០នាក់) និងច្រើនជាងពីរដងនៃអត្រាសកល (៣,៨នាក់ក្នុងចំណោម ១០០.០០០នាក់)។ ការលង់ទឹក គឺជាមូលហេតុនាំមុខនៃការស្លាប់របស់កុមារអាយុ ៥ ទៅ ១៤ឆ្នាំនៅកម្ពុជា។[5]

ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានប្រសាសន៍ថា៖

“ការប្រែប្រួលអាកាសធាតុកំពុងបង្កើនហានិភ័យទាំងនេះ៖ ការធ្លាក់ភ្លៀងមូសុងកាន់តែខ្លាំង និងកាន់តែញឹកញាប់ បង្កឱ្យមានទឹកជំនន់ធ្ងន់ធ្ងរ ដែលធ្វើឱ្យកុមារប្រឈមនឹងហានិភ័យកាន់តែខ្ពស់ចំពោះការលង់ទឹក ស្របពេលដែលព្រឹត្តិការណ៍អាកាសធាតុអាក្រក់ៗបង្កើនហានិភ័យនៃគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក។”

“នៅពីក្រោយតួលេខនីមួយៗ គឺជាសាច់រឿងនៃការបាត់បង់ ពោលគឺ កុមារដែលនឹងមិនវិលត្រលប់មកផ្ទះវិញ គ្រួសារដែលមានភាពសោកសង្រេង និងសហគមន៍ដែលបាត់បង់អនាគតរបស់ខ្លួន។ កុមារគ្រប់រូបមានសិទ្ធិធំលូតលាស់

---

[1] គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក (NRSC) ឆ្នាំ២០២៣ របាយការណ៍ស្តីពី ចំនួនអ្នកស្លាប់ និងរបួសដោយសារគ្រោះថ្នាក់ចរាចរណ៍។

[2] [របាយការណ៍ស្ថានភាពសកលស្តីពី សុវត្ថិភាពចរាចរណ៍ផ្លូវគោក ឆ្នាំ២០២៣]

[3] នៅឆ្នាំ២០១៩ ប្រទេសកម្ពុជាស្ថិតនៅលំដាប់ទី៨ ក្នុងចំណោម ២៧ប្រទេសនៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ពាក់ព័ន្ធនឹងការស្លាប់បាត់បង់ជីវិតដោយសារគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅក្នុងចំណោមកុមារ និងយុវវ័យអាយុក្រោម២០ឆ្នាំ។ [សុវត្ថិភាពផ្លូវគោករបស់កុមារ និងយុវវ័យនៅក្នុងប្រជាជាតិនៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ឆ្នាំ២០១៩]។

[4] [របាយការណ៍ស្ថានភាពសកលរបស់ WHO ស្តីពីការបង្ការការលង់ទឹក ឆ្នាំ២០២៤]

[5] [របាយការណ៍ស្ថានភាពសកលរបស់ WHO ស្តីពីការបង្ការការលង់ទឹក ឆ្នាំ២០២៤]

នៅក្នុងបរិយាកាសប្រកបដោយសុវត្ថិភាព។ ប៉ុន្តែជារៀងរាល់ថ្ងៃ កុមារនៅកម្ពុជាទទួលរងការបាត់បង់ជីវិត ឬរបួស ដោយសារមូលហេតុជាច្រើន ដែលយើងអាចទប់ស្កាត់បាន" នេះជាសម្ដីរបស់បណ្ឌិត វីល ផាកស៍ នាយកយូនីសេហ្វប្រចាំកម្ពុជា។

លោកថ្លែងបន្ថែមទៀតថា "ទោះជាដំណោះស្រាយមួយ គឺជាការមានការពាក់មួកសុវត្ថិភាពឱ្យបានត្រឹមត្រូវ ការបន្ថយល្បឿននៅជិតសាលារៀន ឬការបង្រៀនកុមារអំពីរបៀបហែលទឹក ឬការលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពផ្លូវទឹកក្តី ដំណោះស្រាយទាំងនោះមានលក្ខណៈច្បាស់លាស់។ ដោយធ្វើការងាររួមគ្នា យើងអាច និងត្រូវតែបញ្ឈប់សោកនាដកម្មដែលអាចបង្ការបានទាំងនេះ តាមរយៈការជំរុញការផ្លាស់ប្ដូរប្រកបដោយបរិវត្តកម្ម និងការធ្វើឱ្យការបង្ការទប់ស្កាត់របួសរបស់កុមារជាចំណុចសំខាន់នៃសកម្មភាពរបស់សហគមន៍ គោលនយោបាយ និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ។"

ដើម្បីដោះស្រាយវិបត្តិដែលកំពុងកើនឡើងពាក់ព័ន្ធនឹងរបួសកុមារ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងមហាផ្ទៃ ក្រសួងសាធារណការ និងដឹកជញ្ជូន គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងក្រសួងសុខាភិបាល កំពុងរួមកម្លាំងគ្នាជាមួយយូនីសេហ្វ និងដៃគូសំខាន់ៗក្នុងការធ្វើឱ្យការបង្ការទប់ស្កាត់ក្លាយទៅជាអាទិភាពជាតិ។ ដោយធ្វើការងាររួមគ្នា រាជរដ្ឋាភិបាលកម្ពុជាអាចជំរុញសកម្មភាពដ៏សំខាន់ទាំងពីរនេះបាន៖

ការធ្វើឱ្យផ្លូវថ្នល់កាន់តែមានសុវត្ថិភាពសម្រាប់កុមារ

- កិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតតំបន់សុវត្ថិភាពចរាចរណ៍នៅតំបន់សាលារៀន នៅតាមទីតាំងដែលបានជ្រើសរើស។ តំបន់ទាំងនេះមានការកំណត់ល្បឿន (៣០ គ.មក្នុងមួយម៉ោង) គំនូសឆ្លងផ្លូវសម្រាប់ ថ្មើរជើង សញ្ញាចរាចរណ៍ និងទីតាំងកាន់តែមានសុវត្ថិភាពសម្រាប់ទម្លាក់កូនសិស្សនៅសាលារៀន ដែលធ្វើឱ្យកុមារកាន់តែងាយស្រួលទៅកាន់សាលារៀនដោយគ្មានគ្រោះថ្នាក់។ ការកែលម្អទាំងនេះត្រូវមានរួមគ្នាជាមួយនឹងការអប់រំអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកបែបអនុវត្តជាក់ស្តែងសម្រាប់សិស្សានុសិស្ស គ្រូបង្រៀន ឪពុកម្តាយ និងអាជ្ញាធរមូលដ្ឋាន។ យុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈតាមផ្ទាំងផ្សព្វផ្សាយតាមដងផ្លូវ ទូរទស្សន៍ និងបណ្តាញទំនាក់ទំនងសង្គម ពង្រឹងការអនុវត្តអាកប្បកិរិយាប្រកបដោយសុវត្ថិភាព និងគ្របដណ្តប់ទៅដល់គ្រួសារនានានៅទូទាំងប្រទេស។
- នៅថ្នាក់ជាតិ កំពុងមានការរៀបចំគោលការណ៍ណែនាំថ្មីៗ ដើម្បីកំណត់បទដ្ឋានសុវត្ថិភាពនៅតំបន់សាលារៀន។ ក្រសួង ស្ថាប័នពាក់ព័ន្ធកំពុងសហការគ្នា ដើម្បីពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ ដូចជា គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក (NRSC) ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) និងអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ។ អន្តរាគមន៍ទាំងនេះរួមបញ្ចូលនូវការប្រើប្រាស់មួកសុវត្ថិភាពជាកាតព្វកិច្ច និងទណ្ឌកម្មចំពោះការបើកបរប្រកបដោយគ្រោះថ្នាក់។

ការបង្ការទប់ស្កាត់ការលង់ទឹក

- នៅក្នុងសហគមន៍ កុមារកំពុងរៀនអំពីការហែលទឹក និងសុវត្ថិភាពផ្លូវទឹក ស្របពេលដែលអ្នកថែទាំទទួលបានការណែនាំអំពីការគ្រប់គ្រងកុមារដែលនៅជិតទន្លេ ស្រះទឹក និងតំបន់មានទឹកជំនន់។ កម្មវិធីទាំងនេះត្រូវបានរៀបចំឡើងដើម្បីឱ្យមានចំណាយទាប មានការជំរុញក្នុងមូលដ្ឋាន និងអាចពង្រីកបាននៅទូទាំងកម្ពុជា។
- នៅកម្រិតគោលនយោបាយ រាជរដ្ឋាភិបាលកំពុងដាក់ដំណើរការផែនការយុទ្ធសាស្ត្រជាតិទីមួយស្ដីពីការបង្ការទប់ស្កាត់ការលង់ទឹក (ឆ្នាំ២០២៥-២០៣០) និងផ្តល់សិទ្ធិអំណាចជូនអាជ្ញាធរមូលដ្ឋានដើម្បីធ្វើសមាហរណកម្មសុវត្ថិភាពផ្លូវទឹកទៅក្នុងការរៀបចំផែនការ និងថវិការបស់ខ្លួន។ យុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈក៏កំពុងជួយគ្រួសារឱ្យយល់អំពីរបៀបរក្សាសុវត្ថិភាពរបស់កុមារនៅជិតទន្លេ ស្រះទឹក និងតំបន់ទឹកជំនន់ផងដែរ។

ដោយមានកិច្ចគាំទ្រពីយូនីសេហ្វ និងដៃគូ រាជរដ្ឋាភិបាលកម្ពុជាកំពុងអំពាវនាវឱ្យអាជ្ញាធរសាធារណៈ រួមមានក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ សាលារៀន ឪពុកម្តាយ បណ្តាញយុវជន ប្រព័ន្ធផ្សព្វផ្សាយ ក្រុមហ៊ុនវិ

ស័យឯកជន សហគមន៍ និងបុគ្គលម្នាក់ៗ ដឹកនាំផ្សព្វផ្សាយសារអប់រំអំពីសុវត្ថិភាព។ សម្ភារៈនានាសម្រាប់យុទ្ធនាការទាំងនេះ រួមមាន ផ្ទាំងរូបភាពផ្សព្វផ្សាយ ផ្ទាំងផ្សព្វផ្សាយតាមដងផ្លូវ វីដេអូខ្លីៗតាមទូរទស្សន៍ និងមាតិកាបណ្តាញទំនាក់ទំនងសង្គម ដែលអាចទាញយក និងប្រើប្រាស់បាន https://unicef.link/43aFDXx ។

ដៃគូសំខាន់ៗរួមមាន អង្គការសុខភាពពិភពលោក (WHO), Royal National Lifeboat Institution (RNLI), យូនីសេហ្វប្រចាំប្រទេសបារាំង, អង្គការហែលទឹកកម្ពុជា (HTK), អង្គការ HelpCode, អង្គការ SWIM កម្ពុជា, និងអង្គការមូលនិធិបង្ការរបួសអាស៊ី (AIPF)។ យើងក៏សូមថ្លែងអំណរគុណចំពោះកិច្ចគាំទ្ររបស់ម្ចាស់ជំនួយប្រកបដោយការគោរពរបស់យើង៖ ក្រុមហ៊ុន Michelin ដែលរួមចំណែកចំពោះគំនិតផ្តួចផ្តើមសុវត្ថិភាពចរាចរណ៍ផ្លូវគោក និង Royal National Lifeboat Institution និងមូលនិធិព្រះនាង Charlene នៃប្រទេសម៉ូណាកូ (The Princess Charlene of Monaco Foundation (PCMF)) ដែលសុទ្ធតែមានសារសំខាន់ខ្លាំងនៅក្នុងកិច្ចខិតខំប្រឹងប្រែងបង្ការការលង់ទឹករបស់យើង។

សម្រាប់ព័ត៌មានបន្ថែមអំពីការបង្ការរបួសកុមារ សូមចូលទៅកាន់៖

សុវត្ថិភាពចរាចរណ៍ផ្លូវគោក៖ https://unicef.link/4qfcFzD និងការបង្ការការលង់ទឹក៖ https://unicef.link/4nk5xz7

###

អំពីយូនីសេហ្វ

យូនីសេហ្វធ្វើការងារនៅទីកន្លែងលំបាកបំផុតមួយចំនួន ដើម្បីគ្របដណ្តប់ទៅដល់កុមារស្ថិតក្នុងស្ថានភាពលំបាកបំផុតនៅក្នុងពិភពលោក។ យើងធ្វើការងារនៅក្នុងប្រទេស និងដែនដីជាង ១៩០ ដើម្បីកុមារគ្រប់រូប នៅគ្រប់ទីកន្លែង ដើម្បីកសាងពិភពលោកកាន់តែល្អមួយសម្រាប់មនុស្សគ្រប់រូប។

សម្រាប់ព័ត៌មានបន្ថែមអំពីយូនីសេហ្វ និងការងាររបស់យូនីសេហ្វនៅកម្ពុជា សូមចូលទៅ៖ www.unicef.org.kh

សូមតាមដានអង្គការយូនីសេហ្វប្រចាំកម្ពុជានៅលើ Facebook | Twitter | YouTube | Instagram | LinkedIn | Threads | TikTok

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖
Hadrien Bonnaud ប្រធានផ្នែកទំនាក់ទំនង យូនីសេហ្វប្រចាំកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ២៦០ ២០៤ អ៊ីម៉េល៖ hbonnaud@unicef.org

ចាន់ ទី អ្នកឯកទេសផ្នែកទំនាក់ទំនង យូនីសេហ្វប្រចាំកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ២៦០ ២០៤ អ៊ីម៉េល៖ tchan@unicef.org